-18- ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៣

ចុះថ្ងៃទី១៧ខែមករាឆ្នាំ២០០១

តាងនាមប្រជារាស្ត្រខ្មែរ

សាលដីកា

តុលាការកំពូល

លេខ : ៣៧

ចុះថ្ងៃទី២១ខែកុម្ភៈឆ្នាំ២០០២

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ២១- ខែ កុម្ភៈ ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ :-

១-ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២-លោក វៀល មួន ជាចៅក្រម

៣-លោក ព្រាក់ គឹមសាន ជាចៅក្រម

៤-លោក ជីវ កេង ជាចៅក្រមរបាយការណ៍

៥-លោក យស់ សូខឿន ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី ឃុត សុគន្ធា

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ៥១ "គ" ចុះថ្ងៃទី ១៨-៩-០០ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ៣៨១ ចុះថ្ងៃទី ០២-៦-០០ របស់ សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ គុយ សុម៉ាលី អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរ ជួលកាសែតវីដេអូ ទីលំនៅភូមិកំពង់បាយខាងត្បូង ឃុំកំពង់បាយ ស្រុកកំពង់បាយ ខេត្តកំពត ។ ផ្ទេរសិទ្ធិអោយប្អូនឈ្មោះ គុយ ស៊ីវុត្ថា

មេធាវី : លោក សែម ចិន្តា

និងចុងបណ្តឹងសាទុក្ខឈ្មោះអ្នកស្រី ម៉ៅ មុំ អាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរ- ជួលកាសែតវីដេអូ ទីលំនៅភូមិ១ ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត ។

កម្មវត្ថុបណ្តឹង : ទាមទារសំណងលើតម្លៃអាជីវកម្ម ១៨០០ដុល្លា និង ជម្ងឺចិត្ត ១.៥០០.០០០រៀល ។

បានឃើញបណ្តឹងសាទុក្ខលេខ៤៤៩ ចុះថ្ងៃទី០៨-១១-២០០០របស់លោក គុយ ស៊ីវុត្ថា ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៥១ "គ" ចុះថ្ងៃទី១៨-៩-០០ របស់សាលាឧទ្ធរណ៍ លើ សេចក្តីសំរេចទាំងមូល ។

បាន ឃើញសាលដីការឿងរដ្ឋប្បវេណីលេខ ១៣ ចុះថ្ងៃទី ១៧_០១_០១ របស់
តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៩_១០_៩៩ របស់ឈ្មោះ ម៉ៅ មុំ ថាខ្លួនបានទទួល
សិទ្ធិផ្តាច់មុខរឿង យុទ្ធសិល្បិ៍ទេវតាទាំង៨ ពីក្រុមហ៊ុន ហង្សមាស តាមលិខិតលេខ ១៨៥៣ម
ចុះថ្ងៃទី ១៨_៩_៩៩ និង ភ្ជាប់ដោយទិដ្ឋាការលេខ៤០ វវី ចុះថ្ងៃទី ២២_០៥_៩៩
របស់ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ក្រោយពេលបានទទួលសិទ្ធិផ្តាច់មុខហើយ ខ្លួនក៏ចាប់ធ្វើអាជីវកម្មនៅក្នុងទឹកដីខេត្ត
កំពត ពេលនោះមានឈ្មោះ គុយ សុម៉ាលី បានលួចថតចម្លងរឿងយុទ្ធសិល្បិ៍ទេវតាទាំង៨
របស់ខ្លួន ហើយជួលទៅអោយអតិថិជនក្នុងតំបន់ថោក ។

បន្ទាប់ពីចាប់បានភស្តុតាងគ្រប់គ្រាន់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត បានអោយ
ឈ្មោះ គុយ យុម៉ាលី បញ្ឈប់ការជួលរឿងនេះបន្តទៅទៀត តែឈ្មោះនេះនៅតែបន្ត
ការជួលទៀត ធ្វើអោយខ្លួនខូចផលប្រយោជន៍យ៉ាងខ្លាំង ដូច្នេះពេលនេះខ្លួនសុំទាមទារ
សំណងការខូចខាតចំនួន ១.៨០០ដុល្លា និង ជម្ងឺចិត្ត ១.០០០ដុល្លា ហើយប្រគល់កាសែតអោយ
ធ្វើអាជីវកម្មចុះ។ បានឃើញសាលក្រមលេខ០៩_ចុះថ្ងៃទី២៥_០១_០០ របស់ តុលាការ
ខេត្តកំពត ដែលសំរេចដូចតទៅ :-

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ម៉ៅ មុំ ចុះថ្ងៃទី ១៩_១០_៩៩
ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-អោយឈ្មោះ គុយ សុម៉ាលី សងថ្លៃខូចខាតលើអាជីវកម្មកាសែតវីដេអូ រឿង
យុទ្ធសិល្បិ៍ទេវតាទាំង៨ចំនួន ១.៨០០ដុល្លា និង សំណងជម្ងឺចិត្តចំនួន ២.០០០.០០០រៀល
ទៅអោយឈ្មោះ ម៉ៅ មុំ ចាប់ពីពេលសាលក្រមចូលជាស្ថាពរ ។

ក្នុងករណីរឹងរូសមិនព្រមអនុវត្តតាម ត្រូវរឹបអូសទ្រព្យសម្បត្តិដែលមាន
ដើម្បីលក់ឡាយឡុងសងទៅឈ្មោះ ម៉ៅ មុំ ក្នុងករណីសងមិនគ្រប់ត្រូវដាក់គុកបង្ខំ
រូបកាយ តាមមាត្រា ១២៥ និង ១៣៣ នៃ ច្បាប់ស្តីពីការអនុវត្តសាលក្រមរដ្ឋប្ប-
វេណី ។

៣-បង្គាប់អោយឈ្មោះ គុយ សុម៉ាលី បង់ប្រាក់ប្រដាប់ក្តី ៧.០០០រ,០០ ដើម្បី
តុលាការបានចាត់ការតាមច្បាប់ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ,០០ ដែល
ដើមចោទ បានបង់ទុករួចហើយ តែអោយបង់សងទៅដើមចោទវិញ ។

កាលបើរួសរាយៈពេលថ្លឹងឧទ្ធរណ៍ បង្គាប់អោយឈ្មោះ គុយ សុម៉ាលី បង់ពន្ធ
សមាមាត្រ១ ភាគរយលើប្រាក់ ១.៨០០ដុល្លា ស្មើនឹង ៦.៨៤០.០០០រ,០០ និង ២.០០០.០០០
រៀល ស្មើនឹង $\frac{\text{១ គុណ ៦.៨៤០.០០០ បូក ២.០០០.០០០}}{\text{១០០}}$ ស្មើ ៨៨.៤០០រ,០០ ហើយ
ប្រាក់ពន្ធនេះត្រូវដកយក ៨០ភាគរយ បង់ចូលឃ្លាំងរដ្ឋតី $\frac{\text{៨០ គុណ ៨៨.៤០០រ,០០}}{\text{១០០}}$ ស្មើ

៧០.៧២០៛០០ និង ដកយក ២០ភាគរយបង់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេសគឺ -

២០ គុណ ៨៨.៥០០ / ១០០ ស្មើ ១៧.៦៨០៛០០ ។

សាលក្រមនេះជំនុំជំរះជាសាធារណៈ ប្រកាសជាសាធារណៈ ចំពោះមុខ ដើមចោទឈ្មោះ ម៉ៅ មុំ សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល ២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ និង កំបាំងមុខចុងចម្លើយឈ្មោះ គុយ សុម៉ាលី សំរេចបើកសិទ្ធិប្តឹងជំទាស់រយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ និង រយៈពេល២ខែសម្រាប់ប្តឹងឧទ្ធរណ៍ គិតពីថ្ងៃផុតរយៈពេលប្តឹងជំទាស់ចំពោះ គុយ សុម៉ាលី ។

·សាលក្រមនេះត្រូវបានអ្នកស្រី គុយ សុម៉ាលី ប្តឹងទាស់តាមបណ្តឹងលេខ ០៥ ចុះថ្ងៃទី-០២-០២-១០លើសាលក្រមទាំងមូល ។

បានឃើញសាលក្រមលេខ ២៨ ចុះថ្ងៃទី ១០-៣-០០ របស់តុលាការខេត្តកំពត ដែលសំរេចដូចតទៅ :-

តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៩ ចុះថ្ងៃទី ២៥-០១-០០ របស់ តុលាការខេត្តកំពត ទុកជាបានការពេញទាំងមូល ។

សាលក្រមនេះជំនុំជំរះជាសាធារណៈ ប្រកាសជាសាធារណៈចំពោះមុខគូក្តី សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

សាលក្រមនេះត្រូវបានអ្នកស្រី គុយ សុម៉ាលី ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ១៥ ចុះថ្ងៃទី ១៨-០៥-០០ និង បណ្តឹងលេខ ១៦ ចុះថ្ងៃទី ១៩-៥-០០ របស់អ្នកស្រី ម៉ៅ មុំ លើសាលក្រមទាំងមូល ។

បានឃើញសាលដីកាលេខ ៣៦ "គ" ចុះថ្ងៃទី ២៧-៧-០០ របស់ សាលាឧទ្ធរណ៍ ដែលសំរេចដូចតទៅ :-

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៨-៥-២០០០ របស់ឈ្មោះ គុយ សុម៉ាលី និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៩-៥-០០ របស់ឈ្មោះ ម៉ៅ មុំ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២៨ ចុះថ្ងៃ១០-៣-០០ របស់តុលាការខេត្តកំពត ទុកជាបានការពេញទាំងមូល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីដាក់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛០០គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង២.៥៥០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛០០ ចំណាយលើការប្រគល់ដីការ ៥.០០០៛០០ និងលើអាជ្ញាធរតុលាការ ៥.០០០៛០០ ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខ ម៉ៅ មុំ កំបាំងមុខ គុយ សុម៉ាលី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់របស់អ្នកស្រី គុយ សុម៉ាលី ចុះថ្ងៃទី ០៩-៨-០០ លើ

សាលដីកាទាំងមូល ។

បានឃើញសាលដីកាលេខ ៥១ "គ" ចុះថ្ងៃទី ១៩_៩_០០ របស់សាលាឧទ្ធរណ៍ ដែលសំរេចដូចតទៅ :-

១_ទទួលបណ្តឹងទាស់ចុះថ្ងៃទី ០៩_៨_០០ របស់ឈ្មោះ គុយ សុម៉ាលី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាកំបាំងមុខលេខ ៣៦ "គ" ចុះថ្ងៃទី ២៧_៧_០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣_សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៤៩ ចុះថ្ងៃទី ០៨_១១_០០ របស់លោក គុយ ស៊ីវុត្ថា ធ្វើទៀងក្នុងកំណត់ច្បាប់ ។

បានឃើញសារណារបស់លោក គុយ ស៊ីវុត្ថា ចុះថ្ងៃទី ១៧_០៧_០១ ។

បានឃើញសារណាតបរបស់អ្នកស្រី ម៉ៅ មុំ ចុះថ្ងៃទី០៩_៨_០១ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :-សាលដីកាសាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

បានស្តាប់ចម្លើយរបស់លោក គុយ ស៊ីវុត្ថា ដែលបានឆ្លើយនៅពេលសវនាការថា :- ការសំរេចរបស់សាលាឧទ្ធរណ៍អយុត្តិធម៌ណាស់ ចំពោះរឿងយុទ្ធសិល្ប៍ទេវតាទាំង៨នេះ ខ្លួនទិញនៅតាមទីផ្សារ ហើយដាក់ជួលជាសាធារណៈ ស្រាប់តែចាប់អតិថិជនដែលជួលកាសែតខ្លួន ហើយចោទថាខ្លួនធ្វើអាជីវកម្មប៉ះពាល់សិទ្ធិផ្តាច់មុខរបស់នាងម៉ៅ មុំ ដែល ម៉ៅ មុំ គ្មានទាំងច្បាប់អាជីវកម្មផង គ្រាន់តែក្រុមហ៊ុនធ្វើលិខិតបញ្ជាក់ថាប្រគល់សិទ្ធិផ្តាច់មុខអោយម៉ៅ មុំ ស្រាប់មន្ទីរវប្បធម៌ខេត្តទទួលស្គាល់ថានាង ម៉ៅ មុំ ទទួលសិទ្ធិផ្តាច់មុខស្របច្បាប់ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី ម៉ៅ មុំ ដែលបានឆ្លើយនៅពេលសវនាការថា :- ខ្លួនបង់ពន្ធត្រឹមត្រូវតាមច្បាប់ មានទិដ្ឋាការ ពេលឃើញ គុយ សុម៉ាលី បញ្ចាំងខ្លួនប្តឹងទៅមន្ទីរវប្បធម៌ ។

លិខិតផ្តាច់មុខគឺទិដ្ឋាការដែលក្រុមហ៊ុនចេញអោយជាសំគាល់នូវភាពផ្តាច់មុខស្រប-ច្បាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក សែម ចិន្តា មេធាវីការពារអោយចុងចម្លើយថា :- បើពិនិត្យទៅអ្នកស្រី ម៉ៅ មុំ គ្មានលិខិតផ្តាច់មុខទេ ។ ទិដ្ឋាការជាលិខិតឯកជនរបស់ក្រុមហ៊ុន មិនមែនជាកិច្ចសន្យាសំគាល់នូវការលក់ផ្តាច់មុខរវាងក្រុមហ៊ុន និង សាខាក្រុមហ៊ុនទេ ឯសាខាមិនមានទិដ្ឋាការទេ ។

មន្ទីរវប្បធម៌អះអាងថា ម៉ៅ មុំ មានសិទ្ធិផ្តាច់មុខ ដោយសំអាងលើលិខិតមិនមែនផ្តាច់មុខ ។ ទាំងនេះបញ្ជាក់ថា តុលាការថ្នាក់ក្រោមមិនបានវិភាគពីសិទ្ធិផ្តាច់មុខទេ ហើយនាសវនាការតុលាការថ្នាក់ក្រោម ព្រះរាជអាជ្ញាក៏មិនបានចូលរួមដែរ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៤៩ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០០ របស់លោក គុយ ស៊ីវុត្ថា តំណាងអ្នកស្រី គុយ សុម៉ាលី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការ-កំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អ្នកស្រី គុយ សុម៉ាលី បានប្រើប្រាស់នូវកាសែតវីដេអូរឿងយុទ្ធសិល្បទេវតាទាំង៨ ដែលអ្នកស្រី ម៉ៅ មុំ បានទទួលសិទ្ធិផ្តាច់មុខពីក្រុមហ៊ុន ហង្សមាស ដើម្បីធ្វើអាជីវកម្មនៅក្នុងខេត្តកំពត ។ ប៉ុន្តែ រឿងយុទ្ធសិល្បទេវតាទាំង៨នេះដែលច្បាប់ដើមមានតែ ១៨ភាគ អ្នកស្រីម៉ៅ មុំ បានយកវែងរហូតដល់ ២១ភាគ ។ នាពេលសវនាការនេះលោក គុយ ស៊ីវុត្ថា បានទទួលស្គាល់ថា កាសែតវីដេអូដែលលោកទិញមកពីផ្សារយកមកបញ្ចាំងនេះមាន ២១ភាគដែរ ដូច្នេះបញ្ជាក់អោយឃើញថាអ្នកស្រី គុយ សុម៉ាលិ បានយកផលិតផលផ្តាច់មុខរបស់អ្នកស្រិ ម៉ៅ មុំ មកធ្វើអាជីវកម្មប្រកួតប្រជែងធ្វើអោយខូច ប្រយោជន៍របស់អ្នកស្រីម៉ៅមុំ ប្រាកដមែន ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៥១ "គ" ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០០ របស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៤៤៩ ចុះថ្ងៃទី ០៨-១១-០០ របស់លោក គុយ ស៊ីវុត្ថា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៥១ "គ" ចុះថ្ងៃទី ១៩-៩-២០០០ របស់

សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣_រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រ,០០ ដែលអ្នកស្រី ម៉ៅ មុំ បាន បង់ជួសរួចហើយគឺ :_

_ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៥.០០០រ,០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន៨០០រ,០០ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

_ចំណាយលើការប្រគល់ដីការកោះចំនួន ១៥.០០០រ,០០ សរុប ១៩.០០០រ,០០ ហើយតម្រូវអោយអ្នកស្រី គុយ សុម៉ាលី សងប្រាក់ ១៩.០០០រ,០០នេះទៅអ្នកស្រី ម៉ៅ មុំ វិញ ។

បង្គាប់អោយអ្នកស្រី គុយ សុម៉ាលី បង់ពន្ធសមាមាត្រតាមការកំណត់របស់ តុលាការខេត្តកំពត ។

៤_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២ ។